ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ៦៨៨ /១៦-១១-២០០៩

**សាលដីកា**

លេខ : ៨៨(ត)/០៣-១១-២០១០

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៣-១១-២០១០ ដោយ មានសមាសភាពដូចតទៅ :

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក[redacted] ចៅក្រមប្រឹក្សា

លោក[redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:៦៨៨ ចុះថ្ងៃទី ១៦-១១-២០០៩ រវាង :

១-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិរកាកោង ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ទីលំនៅមុនពេលចាប់ខ្លួននៅផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ម្តាយឈ្មោះ[redacted] ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី ២៣-៣-០៩

មេធាវី[redacted]



Scanned by CamScanner

53/3

២-ជនជាប់ចោទឈ្មោ [redacted] ទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីមិនពិតប្រាកដ កើតនៅភូមិកណ្តាល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តកណ្តាល ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោ [redacted] ម្តាយឈ្មោ [redacted] នៅលីវ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី២៣-៣-០៩

៣-ជនជាប់ចោទឈ្មោះ [redacted] ទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីជាងកាត់សក់ កើតនៅភូមិកណ្តាល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តកណ្តាល ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោ [redacted] ទៅលីវ ទោសពីមុនគ្មាន ។ ឃុំខ្លួន ថ្ងៃទី២៣-០៣-០៩

ត្រូវចោទពីបទ : ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២០-០៣-២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមបញ្ញត្តិ នៃមាត្រា ០៦ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ [redacted] ទស្រី អាយុ៤៩ឆ្នាំ ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ៣៧អឺ១ ផ្លូវលេខ៣១៦ ក្រុមទី៣៦ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥-០៩-២០០៩ របស់ជនជាប់ចោទឈ្មោ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ:៨៣ (កប៥) ចុះថ្ងៃទី០៨-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

**ដំណើររឿងហេតុមានដូចតទៅ:**

កាលពីថ្ងៃទី ២០-០៣-២០០៩ វេលាម៉ោងប្រហែល ១៧:០០នាទី កំលាំងល្បាតរបស់ការិយាល័យព្រហ្មទណ្ឌកិរិតស្រាល នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ បានល្បាតត្រង់ចំណុចស្តាតអូឡាំពិក បានឃើញជនសង្ស័យចំនួន ០៣នាក់ ជិះម៉ូតូ០២គ្រឿង មួយម៉ាកស្មាសវីវ៉ូពណ៌ខ្មៅ ឆ្នាំ២០០៧ ពាក់ស្លាកលេខ ភ.ព ១អូ៦២០០. ទីពីរ ម៉ាកហុងដា ១០០ពណ៌ខ្មៅឆ្នាំ១៩៩៩ បានធ្វើសកម្មភាពឆក់ខ្សែកពីនារីម្នាក់ដែលកំពុងជិះម៉ូតូម៉ាកគុបម្នាក់ឯង ដោយមានការស្រែកឱ្យជួយពីជនរងគ្រោះ កម្លាំងយើងបានដេញចាប់ លុះមកដល់ចំណុចផ្លូវមុនីវង្សកែងផ្លូវ៣១០ ទើបធ្វើការឃាត់ ខ្លួនជនសង្ស័យបាន ០៣នាក [redacted]

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ: ៨៣ (កប៥) ចុះថ្ងៃទី ០៨-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១-ផ្តន្ទាទោសលើ :

ក-ឈ្មោះ [redacted] យុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៧ឆ្នាំ (ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២០-០៣-២០០៩ ។

ខ-ឈ្មោ [redacted] អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២០-០៣-២០០៩ ។

គ-ឈ្មោះ [redacted] អាយុ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី២០-០៣-២០០៩ ពីបទ ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-០៣-២០០៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



Scanned by CamScanner

២-វត្ថុតាងរួមមាន :

-ម៉ូតូ០១គ្រឿងម៉ាកស្មាសិរីរៃ ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០០៧ ពាក់ស្លាកលេខ ភ្នំពេញ1O-6290 លេខតួ និងលេខម៉ាស៊ីន ~~E450-TH210793~~ ។

-ម៉ូតូ០១គ្រឿងម៉ាក សេ-១០០ ពណ៌ខ្មៅ ស៊េរីឆ្នាំ១៩៩៩ ផលិតនៅប្រទេសចិនពាក់ស្លាកលេខណ៣៤៦២ភព១ ដែលមានលេខតួ និងលេខម៉ាស៊ីន EPSOMG-3* I0472044 * ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

-ខ្សែកថ្លាទីនចំនួន០១ខ្សែ ប្រវែង២តឹកកន្លះ ត្រូវប្រគល់ឱ្យឈ្មោ[redacted]តាមកំណត់ហេតុប្រគល់សម្ភារៈ ចុះថ្ងៃទី ២១-០៣-២០០៩ របស់ការិយាល័យប្រហ្មទណ្ឌក្រិតស្រោលរួចហើយ ។

៣-សាលក្រមជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨-០៩-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោ[redacted] មេធាវីការពារ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]បើក ផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី ០២-០២-២០១០ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោ[redacted]ឆ្លើយបញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនពុំបានប្រព្រឹត្តទេ ខ្លួនបើកម៉ូតូ អ្នកជិះក្រោយឈ្មោះ[redacted]ខ្លួនមិនដឹងអីទេ ប៉ូលីសចាប់ខ្លួនតែម្តង ។ នៅពេលខ្លួនជិះម៉ូតូទៅពោធិ៍ចិនតុង ខ្លួនជាអ្នកឌុប ពេលប៉ូលីសចាប់ខ្លួន ខ្សែកនៅឈ្មោះធឿន ខ្លួនមិនដឹងថា ឈ្មោះធឿន ឆក់ខ្សែកគេទេ ។ ខ្លួនសុំលើកលែងទោស ។

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន : ឆ្លងតាមចម្លើយជនជាប់ចោទ និងតាមការសន្និដ្ឋានរបស់ថ្នាក់ក្រោម ឃើញថា គ្រប់គ្រាន់ សុំតម្កល់ការចោទប្រកាន់ដដែល ។

មេធាវីផ្តល់សេចក្តីសន្និដ្ឋាន : យោងតាមកំណត់ហេតុថ្នាក់ក្រោម កូនក្តីខ្លួនមិនបានដឹងទេ ព្រោះគាត់ជាអ្នកបើកម៉ូតូ សុំតុលាការពិចារណា និងសុំសំរាលទោស ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ ។

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩-០៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ៨៣ (កប៥) ចុះថ្ងៃទី០៨-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តី សម្រេចធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួល ជំនុំជំរះបាន ។



Scanned by CamScanner

២-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយនៅពេលសវនាការថា ខ្លួនបានឧបឈ្មោះ[redacted]នៅថ្ងៃកើតហេតុ ។ ខ្លួនមិនបានដឹងថាឈ្មោះ[redacted]ធ្វើសកម្មភាពអ្វីទេ ប៉ុន្តែតាមចម្លើយនៅដំណាក់កាលស៊ើបអង្កេតឃើញថា ខ្លួនជាអ្នកឱប ហើយឈ្មោះ[redacted]អ្នកឆក់យកខ្សែក ដែលមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយជនរងគ្រោះ ។

៣-សាលាដំបូងបានអង្កេតចប់សព្វគ្រប់ដូចបានសំអាងហេតុនៅក្នុងសាលក្រមរួចហើយ សាលាឧទ្ធរណ៍ឯកភាពដោយមិនចាំបាច់លើកយកមកសរសេរបញ្ជាក់ឡើងវិញទេ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ៨៣ (កប៥) ចុះថ្ងៃទី០៨-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍ តម្កល់សាលក្រមខាងលើទុកជាបានការ ។

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-០៩-២០០៩ របស់ជនជាប់ចោទឈ្មោះ[redacted]ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៣ (កប៥) ចុះថ្ងៃទី០៨-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៨៣ (កប៥) ចុះថ្ងៃទី០៨-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ[redacted] ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ បើកប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា : [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ... ខែ 11 ឆ្នាំ២០១០

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

[redacted]



Scanned by CamScanner